**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
**អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ**
**នីហរណ៍ អាហរណ៍ និងបង្ក្រាបការក្លែងបន្លំ**
" **កាំកុងត្រូល** "

# សេចក្តីជូនដំណឹង

អគ្គនាយកដ្ឋានកាំកុងត្រូលនៃក្រសួងពាណិជ្ជកម្ម សូមជូនដំណឹងដល់ក្រុមហ៊ុន និងម្ចាស់ស្ថានីយ / ដេប៉ូលក់ប្រេងឥន្ធនៈទូទាំងព្រះរាជាណាចក្រកម្ពុជាទាំងអស់ ជ្រាបថា អនុវត្តតាមតួនាទីភារកិច្ចដែលបានផ្តល់អណ្ណត្តិដោយច្បាប់ បទប្បញ្ញត្តិ ជាធរមាន មន្ត្រីជំនាញផ្នែកប្រេងឥន្ធនៈរបស់អគ្គនាយកដ្ឋានកាំកុងត្រូល បានចុះត្រួតពិនិត្យ និងបានរកឃើញនូវភាពមិនសមស្របចំពោះការចរាចរ ចែកចាយ លក់ ប្រេងឥន្ធនៈទាំងលើផ្នែកបរិមាណ គុណភាព និងការប្រកាសដោយបន្លំពីសំណាក់ស្ថានីយ/ ដេប៉ូលក់ប្រេងឥន្ធនៈ មួយចំនួន ហើយបានដាក់នូវវិធានការណ៍ដាក់លាក់តាមនីតិវិធី។

ជាមួយនឹងវិធានការណ៍នេះ មានជនខិលខូចមួយចំនួន បានឆ្លៀតបន្លំខ្លួន ឬប្រើប្រាស់តួនាទីជាមន្ត្រីកាំកុងត្រូល ដើរទារប្រាក់ពីម្ចាស់ស្ថានីយ / ដេប៉ូលក់ប្រេងឥន្ធនៈ ដោយអះអាងជាថ្នូនឹងការជួយដោះស្រាយបញ្ហា ឬសម្របសម្រួលលើបាតុភាពណាមួយ ជាដើម។

ដើម្បីទប់ស្កាត់កុំឱ្យជនខិលខូច បន្លំឆ្លៀតឱកាសឆបោកយកផលប្រយោជន៍ដោយខុសច្បាប់ ព្រមទាំងដើម្បីវែកមុខជនខិលខូចទាំងនោះឱ្យទទួលខុសត្រូវចំពោះមុខច្បាប់ អគ្គនាយកដ្ឋានកាំកុងត្រូល សូមបញ្ជាក់ជូនថា នៅរៀងរាល់ប្រតិបត្តិការការងារ មន្ត្រីជំនាញរបស់កាំកុងត្រូល តែងតែប្រើប្រាស់រថយន្តមន្ទីរពិសោធន៍ចល័ត បំពាក់ដោយសម្ភារៈឧបករណ៍ម៉ាស៊ីនវិភាគ រួមទាំងសំលៀកបំពាក់ជាឯកសណ្ឋានការងារ និងមានលិខិតបញ្ជាបេសកកម្មត្រឹមត្រូវច្បាស់លាស់។

ទន្ទឹមនេះ ប្រសិនបើម្ចាស់ស្ថានីយ / ដេប៉ូលក់ប្រេងឥន្ធនៈ មានការសង្ស័យជាយថាហេតុណាមួយ សូមសហការជាមួយសាខាកាំកុងត្រូលប្រចាំរាជធានី-ខេត្ត តាមគ្រប់វិធីដែលអាចធ្វើទៅបាន។

**លេខទូរស័ព្ទទំនាក់ទំនង:**

- ទូរស័ព្ទខ្សែទី ១ **០១២ ៥២៦ ៦៦០**
- ទូរស័ព្ទខ្សែទី ២ **០១២ ២៧៨ ៧៨៩**
- ទូរស័ព្ទខ្សែទី ៣ **០១២ ៦៩៨ ១៦៩**

អគ្គនាយកដ្ឋានកាំកុងត្រូលនៃក្រសួងពាណិជ្ជកម្ម សង្ឃឹមជឿជាក់ចំពោះការយកចិត្តទុកដាក់ និងកិច្ចសហការល្អរបស់បណ្តាស្ថានីយ / ដេប៉ូលក់ប្រេងទាំងអស់ ដើម្បីការពារផលប្រយោជន៍ជូនវិស័យឯកជន និងផលប្រយោជន៍ប្រជាពលរដ្ឋ ព្រមទាំងដើម្បីជានាឱ្យបរិយាកាសធុរកិច្ចកាន់តែប្រសើរ។

សូមអរគុណ!

ថ្ងៃព្រហស្បតិ៍ ១៥កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ២០១៨

**អគ្គនាយកដ្ឋានកាំកុងត្រូល**